# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនអាជ្ញាធរខេត្តសៀមរាប ថែរក្សា និងគ្រប់គ្រង "សណ្ឋាគារវីឡាអប្សរា"

៚✻៛

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បទបញ្ជាលេខ ៣០/បប ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់រាជរដ្ឋាភិបាល

-អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបដិសេធមិនទទួលស្គាល់សិទ្ធិរបស់តំណាងសាលាខេត្តសៀមរាប ក្នុងការងារចុះកិច្ចសន្យាជួលសណ្ឋាគារវីឡាអប្សរា

-តាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំរេច

**មាត្រា១ :** -កែសំរួលខ្លឹមសារមាត្រា៣ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០០ ទៅជា "ប្រគល់សិទ្ធិជូនអាជ្ញាធរខេត្តសៀមរាប ថែរក្សា និងគ្រប់គ្រងសណ្ឋាគារវីឡាអប្សរា លើផ្ទៃដីចំនួន ៥.៧៩៧ ម៉ែត្រក្រឡា ដើម្បីបំរើទិសដៅស្ពារ និងអភិវឌ្ឍន៍ដោយផ្អែកតាមច្បាប់ និងបទបញ្ញត្តិជាធរមាន" ។

-ក្រៅពីនេះ មាត្រាដទៃទៀតត្រូវរក្សាទុកខ្លឹមសារដដែល ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប និងគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ៣ ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

__ចំលងជូន :__

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា២

-ឯកសារ - កាលប្បវត្តិ